ពេលស្វាមីនិងភរិយាកើតមានការស្អប់ខ្ពើមគ្នាខ្លាំងទៅវិញទៅមក   ភរិយាសូមប្រគល់ទ្រព្យផ្ទាល់ខ្លួនមួយប៉ែកឲ្យទៅស្វាមី ដើម្បីនឹងសូមឲ្យស្វាមីនោះព្រមលែងលះខ្លួន ។ ការលែងលះបែបនេះហៅថាការលែងលះ មូបារ៉ត្តុ់ ។[2540]



# نِكَاح

# នីកាហ៍

## (អាពាហ៍ពិពាហ៍)

ភរិយានោះធ្លាប់តែរស់នៅរហូតមកដល់ពេលនេះ ដើម្បីធ្វើការរង់ចាំរយៈពេលអ៊ីដ្ឋដ្ឋាស្ទ់ឲ្យចប់បរិបូរ លើកលែងតែភរិយានោះបានប្រព្រឹត្តអំពើ លាមកដូចជាប្រព្រឹត្តខុសផ្លូវភេទឬមានសហាយស្មន់ជាដើម ។ ភរិយាក៏ត្រូវបោមចេញពីក្នុងផ្ទះដែរ បើមិនចាំបាច់ ដោយគ្មានការអនុញ្ញាតពីស្វាមី ។2532

## ការលែងលះ ឃុលអ៊ី (اَلطَّلَاقُ اَلْخُلْعِيْ)

ពេលភរិយាកើតមានការស្អប់ខ្ពើមខ្លាំង ចំពោះស្វាមីខ្លួនស្នើសូមប្រគល់ខាន់ស្លាឲ្យ ស្វាមីវិញឬទ្រព្យផ្ទាល់ខ្លួនមួយប៉ែក ដើម្បីសូមឲ្យស្វាមីនោះលែងលះខ្លួន ។ ការលែងលះបែបនេះហៅថាការលែងលះ ឃុលអ៊ី ។ ការលែងលះនេះមានសុពលភាព ពោលគឺត្រឹមត្រូវស្របច្បាប់ ទាល់តែភរិយានោះស្អប់ខ្ពើមនិងមានទោសៈចំពោះស្វាមីខ្លួន ដល់ថ្នាក់មិនព្រមគោរពសិទ្ធិស្វាមី ដែលមានលើភរិយាទេ (ពោលគឺមិនឲ្យស្វាមីរួមដំណេកជាមួយទេ) ។791-2537

## ការលែងលះ មូបារ៉ត្ដុំ (اَلطَّلَاقُ اَلْمُبَارَاةُ)

ឃុលអ៊ី (اَلطَّلَاقُ اَلْخُلْعِيْ) និងការលែងលះដែលគេហៅថា មូបារ៉ត់ (اَلطَّلَاقُ اَلْمُبَارَاةُ) ។

៦. ការលែងលះដែលបានធ្វើដោយលោកមុច្ចតាហ៊ីដ្ (គឺអាជ្ញាធរជំនាញខាងសាសនា) ក្នុងករណីដែលស្វាមីមិនព្រមចិញ្ចឹមនិងមិនព្រមលែងលះភរិយាខ្លួន ។

## ការលែងលះដែលអាចបកក្រោយវិញបាន (ត៉ុឡាក់ រីច្ចអ៊ី الطلاق الرجعي)

ក្រៅពីការលែងលះ ៦ ប្រការខាងលើនេះ ការលែងលះឯទៀតជាការលែងលះរីច្ចអ៊ី (គឺអាចបកក្រោយវិញបាន) បានសេចក្តីថា ដរាបណាស្ត្រីដែលត្រូវលែងលះនៅក្នុងរយៈពេលរង់ចាំអ៊ីដ្ដាស់នៅឡើយ ដរាបនោះស្វាមីស្ត្រីនោះអាចយកស្ត្រីនោះវិញ បានដោយមិនបាច់ធ្វើអ្វីឡើយ ។[790]

ពេលស្វាមីលែងលះភរិយា ដោយការលែងលះរីច្ចអ៊ី ហាមស្វាមីនោះដេញភរិយានោះចេញពីក្នុងផ្ទះ ដែល



# បញ្ជីមាតិកា


ឃុត្បាស់នីកាស់................................................................ ៦
របៀបសូត្រនីកាស់ (ឬ រូបមន្តអាពាហ៍ពិពាហ៍ ឬ ស្វីកោះត៉ុ صِيغَة)....... ១០
លក្ខខណ្ឌសូត្ររូបមន្តអាពាហ៍ពិពាហ៍ (صِيغَة) .................................. ១៦
ប្រការដែលបណ្តាលឲ្យអាពាហ៍ពិពាហ៍មោឃៈ................................ ១៩
មនុស្សដែលហាមរៀបការជាមួយ..................................................២២
មើលស្ត្រីមិនមែនម៉ាស់រ៉ម (គឺស្ត្រីសះនីកាស់)................................. ២៦
ត៉ុឡាក់ (ការលែងលះ)..............................................................៣០
រយៈពេលរង់ចាំពេលលែងលះ (اَلْعِدَّةُ)............................................ ៣៣
រយៈពេលរង់ចាំពេលស្វាមីស្លាប់ ...................................................៣៥
ការលែងលះដែលមិនអាចបកក្រោយវិញបាន (ត៉ុឡាក់ បាអ៊ីន الطلاق البائن) ................................................................................... ៣៧
ការលែងលះដែលអាចបកក្រោយវិញបាន (ត៉ុឡាក់ រីច្ចអ៊ី الطلاق الرجعي) ...................................................................................៣៨
ការលែងលះ ឃុលអ៊ី (اَلطَّلَاقُ اَلْخُلْعِيْ)...................................................៣៩
ការលែងលះ មូបារ៉ត់ (اَلطَّلَاقُ اَلْمُبَارَاةُ) ...................................................៣៩

## ការលែងលះដែលមិនអាចបកក្រោយវិញបាន (ត៉ុឡាក់ បាអ៊ីន الطلاق البائن)

ត៉ុឡាក់ បាអ៊ីន (មិនអាចបកក្រោយវិញបាន) មានន័យថា ក្រោយពីបានលែងលះហើយ ស្វាមីមិនមានសិទ្ធិយកភរិយាវិញទេដោយពុំបានរៀបការសាថ្មីនោះ ។ ការលែងលះនេះមានប្រាំមួយប្រភេទ គឺ៖

១. ការលែងលះរបស់ភរិយាដែលពុំទាន់មានអាយុគ្រប់ ៩ ឆ្នាំ ។

២. ការលែងលះរបស់ភរិយាដែលឈប់មានរដូវ (يَائِسَة) ។

៣. ការលែងលះរបស់ភរិយា ដែលពុំបានរួមភេទជាមួយស្វាមីទេ ក្រោយពីបានរៀបការរួច ។

៤. ការលែងលះរបស់ភរិយា ដែលស្វាមីបានលែងលះជាលើកទីបី ។

៥. ការលែងលះដែលគេហៅថា ឃុលអ៊ុ (اَلطَّلَاقُ اَلْخُلْعُ) ឬ

ជាមួយស្វាមីស្លាប់នោះក៏ដោយ ។

តែ បើភរិយានោះមានផ្ទៃពោះ ភរិយានោះត្រូវរង់ចាំសម្រាលកូនរួច ។ តែបើកូនកើតមុនផុតរយៈពេលរង់ចាំលែងលះបួនខែនិងដប់ថ្ងៃនោះ ចាប់រាប់ពីពេលស្វាមីស្លាប់មក ភរិយានោះត្រូវតែរង់ចាំឲ្យចប់រយៈពេលរង់ចាំនោះ ។ រយៈពេលរង់ចាំនេះហៅថារយៈពេលរង់ចាំក្រោយមរណៈភាព (អ៊ីដ្ដុដ្ដាទុ៎ល-វ៉ាហ្វាត់ុ عِدَّة اَلْوَفَاة) ។[786-2526]

រយៈពេលរង់ចាំក្រោយមរណៈភាពចាប់ផ្ដើម ក្នុងករណីដែលស្វាមីអវត្តមានឬបាត់ខ្លួន ពីពេលគេប្រកាសថាស្វាមីនោះស្លាប់ ថ្ងៃដែលភរិយាបានទទួលដំណឹងថាស្វាមីខ្លួនស្លាប់ មិនមែនពេលដែលស្វាមីនោះស្លាប់មែនទេ ។ តែមិនប្រើច្បាប់នេះលើភរិយាដែលមិនទាន់គ្រប់អាយុ ឬដែលវិកលចរិតនោះទេ ។[787-2529]

ហាមភរិយា ដែលកំពុងអនុវត្តិការរង់ចាំក្រោយមរណៈភាព ស្លៀកពាក់សំលៀកបំពាក់ដែលមានពណ៌ឆើតឆាយ ផាត់មុខ លាបក្រែម លាបម្សៅនិងតែងខ្លួន ។[788-2527]



# نِكَاح នីកាស់ (អាពាហ៍ពិពាហ៍)

ទំនាក់ទំនងរវាងបុរសនិងស្ត្រីទៅជាប្ដីប្រពន្ធ (ស្របច្បាប់) បន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ ។ អាពាហ៍ពិពាហ៍មានពីរប្រភេទ គឺ៖

១. អាពាហ៍ពិពាហ៍អចិន្ត្រៃយ៍ (រហូត) ។

២. អាពាពិពហ៍មានពេលកំណត់ពេល (اَلْمُتْعَة មុតអ្ុាស់ុ)

នៅក្នុងអាពាហ៍ពិពាហ៍អចិន្ត្រៃយ៍ ពុំមានកំណត់ពេលទេ គឺមានរយៈពេលរហូត ។ គេហៅស្ត្រីដែលរៀបការបែបនេះថា ដ្វាអ៊ីម៉ាស់ុ (الدائمة ភរិយាអចិន្ត្រៃយ៍) ។

នៅក្នុងអាពាហ៍ពិពាហ៍មានកំណត់ពេល (មុតអ្ុាស់ុ) រយៈពេលរួមរស់ជាគូស្វាមីភរិយា ត្រូវកំណត់ជាមុនស្រេច ។ ឧទាហរណ៍ បុរសស្ត្រីអាចធ្វើកិច្ចព្រមព្រៀងរួមរស់ជាមួយគ្នាជាគូស្វាមីភរិយាបានមួយម៉ោង មួយថ្ងៃ មួយខែ មួយឆ្នាំ ឬលើសពីនេះ ។ តែរយៈពេលអាពាហ៍ពិពាហ៍នេះមិនត្រូវលើសពីរយៈពេលរស់នៅរបស់គូស្វាមីភរិយាទេ (គឺពេល

នៅរស់) ពុំនោះទេអាពាពិពាហ៍នេះត្រូវចាត់ទុកជាអាពាហ៍ពិពាហ៍អចិន្ត្រៃយ៍ ។ គេហៅស្ត្រីដែលរៀបការបែបនេះដោយមានកំណត់ពេលថា ម៉ាំទូអ៊ុស្ញ់ ឬ ស្ទីក៉េុះត្ញ៍ ។

## ឃុត្ញបាស់នីកាស់

សូត្រឃុត្ញបាស់នីកាស់មុនសូត្ររូបមន្តនីកាស់ នៅក្នុងទង្វើមុស្តាហ្ញាប់ (ពោលគឺ មិនចាំបាច់) ។

الْحَمْدُ لِلّٰهِ الَّذِيْ خَلَقَ آدَمَ مِنْ صَلْصَالٍ كَالْفَخَّارِ

សូមថ្វាយសេចក្ដីកោតសរសើទាំងអម្បាលម៉ាន ចំពោះអល់ឡោះហ៊្ញ عز وجل ដែលបានបង្កើតអាដាំ عليه السلام ពីដីស្ងួត ដូចភាជន៍ធ្វើពីដី ។

وَ خَلَقَ زَوْجَتَهُ حَوَّآءَ جَلِيْلَةَ الْمِقْدَارِ

ហើយព្រះអង្គ عز وجل បានបង្កើតហាវ៉ាអ៊ុ سلام الله عليها ភរិយាព្រះអង្គ عز وجل ជាគូស្រករឧត្តម ។

فَتَنَاكَحَا وَتَنَاسَلَا خَلْقًا كَثِيْرًا مِنْ عَبِيْدٍ وَ اَحْرَارٍ



ពីបានលែងលះរួច លើកលែងតែភរិយានោះឃើញមានស្នាមទឹកកាមរបស់ស្វាមីនៅលើខ្នាស ក្នុងករណីនេះភរិយានោះ ត្រូវអនុវត្តិរយៈពេលរង់ចាំលែងលះ (អ៊ីដ្ញដ្ញាស្ញ់) ។784-2520

បើស្ត្រីលែងលះពីស្វាមីបន្ទាប់ពីបានរួមភេទ តែស្ត្រីនោះមិនឃើញមានរដូវទេ ថ្វីដ្បិតស្ត្រីនោះនៅក្នុងវ័យស្ត្រីដែលមានរដូវជាធម្មតា ស្ត្រីនោះចាំបាច់ត្រូវអនុវត្តិរយៈពេលរង់ចាំលែងលះចំនួនបីខែក្រោយពីបានលែងលះរួច មុននឹងអាចរៀបការថ្មីបាន ។785-2521

## រយៈពេលរង់ចាំពេលស្វាមីស្លាប់

បើស្វាមីស្លាប់ ភរិយាមិនមានផ្ទៃពោះទេ ភរិយានោះចាំបាច់ត្រូវរង់ចាំបួនខែនិងដប់ថ្ងៃ បានសេចក្ដីថាភរិយានោះមិនត្រូវរៀបការថ្មីនៅក្នុងអំឡុងពេលនេះទេ ទោះបីភរិយានោះជាស្ត្រីឈប់មានរដូវ (يَائِسَة) ហើយក៏ដោយ ទោះបីភរិយានោះបានរៀបការ ដោយមានកំណត់ពេល (មុតអ៊ុស្ញ់) ក៏ដោយ ទោះបីភរិយានោះពុំបានរួមភេទ

ស្ត្រីដែលពុំទាន់ដល់អាយុ ៩ ឆ្នាំទេ និងស្ត្រីដែលឈប់មានរដូវ (يَائِسَة) មិនចាំបាច់រង់ចាំអ៊ីដ្ទដ្ទាស្ទុំទេ ។ បានសេចក្ដីថា ទោះបីស្ត្រីនោះបានលែងលះពីស្វាមីក្រោយពីបានរួមភេទជាមួយស្វាមីនោះក៏ដោយ ស្ត្រីនោះអាចរៀបការជាមួយស្វាមីផ្សេងបានភ្លាមៗ ។783-2519

បើស្ត្រីដែលមានអាយុគ្រប់ ៩ ឆ្នាំហើយជាស្ត្រីដែលមិនទាន់ឈប់មានរដូវទេ (មិនមែនស្ត្រី يَائِسَة ទេ) បានលែងលះពីស្វាមី ក្រោយពីបានរួមភេទជាមួយស្វាមីនោះ ចាំបាច់ត្រូវអនុវត្តរយៈពេលរង់ចាំលែងលះ ។ រយៈពេលរង់ចាំរបស់ស្ត្រីគឺ បើស្ត្រីបានលែងលះពីស្វាមីក្នុងអំឡុងពេលដែលស្ត្រីនោះពុំមានរដូវទេ ស្ត្រីនោះចាំបាច់ត្រូវតែរង់ចាំទាល់តែមានរដូវពីរដងហើយជ្រះស្អាតពីរដូវខែនោះវិញ ។ បន្ទាប់ពីនោះ ពេលស្ត្រីនោះមានរដូវជាលើកទីបី រយៈពេលរង់ចាំរបស់ស្ត្រីនោះបានចប់បរិបូរ ស្ត្រីនោះអាចរៀបការថ្មីបាន ។ តែបើស្វាមីបានលែងលះភរិយាមុនបានរួមភេទជាមួយភរិយានោះ ភរិយានោះមិនចាំបាច់រង់ចាំទេ ភរិយានោះអាចរៀបការជាមួយស្វាមីថ្មីភ្លាមៗបាន បន្ទាប់



ព្រះអង្គទាំងពីរعليهم السلام បានរៀបមង្គលការអាពាហ៍ពិពាហ៍ បានចាប់ផ្ដើមបង្កបង្កើតមនុស្សជាតិ ច្រើនលើសលុប ទាំងបណ្ដាអ្នកនៅក្នុងបន្ទុកគេ ទាំងបណ្ដាអ្នកមានសេរីភាព ។

وَتَوَالَدَ الْإِنَاثَ وَالذِّكَارَ

បានឲ្យកំណើតដល់កូនស្រីនិងកូនប្រុស ។

وَ الْحَمْدُ لِلّٰهِ الَّذِيْ اَمَرَنَا بِالنِّكَاحِ وَ رَغَبَ فِيْهِ

សូមថ្វាយសេចក្ដីសរសើរទាំងម្បាលម៉ាន ចំពោះអល់ឡោះហ៍عزوجل ដែលបានដាក់មក នូវមង្គលការអាពាហ៍ពិពាហ៍ (នីកាស្ទុំ) និងធ្វើឲ្យវាគួរឲ្យចង់បាន ។

حَيْثُ قَالَ فِي الْكِتَابِ الْمَجِيْدِ وَالْفُرْقَانِ الْحَمِيْدِ

ព្រះអង្គعزوجلមានព្រះបន្ទូលនៅក្នុងព្រះគម្ពីររុងរឿង និងជាទីកោតសរសើរ អាល់-ហ្វូរក្វូនថា៖

بِسْمِ اللّٰهِ الرَّحْمٰنِ الرَّحِيمِ

وَاَنْكِحُوْ اْلاَيَا مىَ مِنْكُمْ وَالصَّالِحِيْنَ مِنْ عِبَادِكُمْ وَاِمَآءِكُمْ اِنْ يَّكُوْنُوْا فُقَرَآءَ يُغْنِهِمُ اللهُ مِنْ فَضْلِهِ وَاللهُ وَاسِعٌ عَلِيْمٌ.

"ដោយនូវព្រះនាម អល់ឡោះហ្ទ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តា ករុណាប្រណី ។

ចូរពួកអ្នករៀបការឲ្យមនុស្សលីវ ឲ្យបណ្ដាទាសៈ[និងបម្រើ] និងបណ្ដាទាសីរបស់ពួកអ្នកដែលជាមនុស្សត្រឹមត្រូវ[និងស្មោះត្រង់]។ បើពួកគេទ័លក្រ អល់ឡោះហ្ទ៍នឹងជួយឲ្យពួកគេមានបាន អាស្រ័យឧបការគុណព្រះអង្គ ។ អល់ឡោះហ្ទ៍មានព្រះហឫទ័យទូលំទូលាយ ព្រះអង្គទ្រង់ញាណ ។ (ស៊ូរ៉ោះត្ទ៍ អាន់-នូរ (24) អាយ៉ាស្ទ៍ 32)

وَ قَالَ سَيِّدُ الْمُرْسَلِيْنَ وَ خَاتِمُ النَّبِيِّيْنَ حَبِيْبُ قُلُوْبِنَا وَ طَبِيْبُ نُفُوْسِنَا اَبُوْ اَلْقَاسِمِ مُحَمَّدٌ (صَلَّى اللّٰهُ عَلَيْهِ وَ آلِهِ)

ព្រះអគ្គមហាប្រមុខរបស់ព្រះសាស្ដាទាំងពួង ព្រះសាស្ដាចុងក្រោយបង្អស់ មហាបុគ្គលជាទីស្រឡាញ់របស់យើង មហាបុគ្គលអ្នកព្យាបាលវិញ្ញាណយើង អាប៊ុល-ក្ទ៍ស៊ីម មូហ្ចាំម៉ាដ្ទ៍ ﷺ មានព្រះវចនៈថា៖



زَوْجَتِيْ فَاطِمَةُ طَالِقٌ

ស៊ៅយ៉ាត្ទី ហ្វាទ្ទីម៉ាស្ទ៍ ត្ទ៍លិក្ទ

(ហ្វាទ្ទីម៉ាស្ទ៍ភរិយាខ្ញុំត្រូវលែងលះ)

បើស្វាមីតែងតាំងអ្នកតំណាង (វ៉ាគីល وكيل) ដើម្បីសូត្រលែងលះជំនួសខ្លួន អ្នកតំណាងនោះត្រូវសូត្រថា៖

زَوْجَةُ مُوَكِّلِيْ فَاطِمَةُ طَالِقٌ

ស៊ៅយ៉ាត្ទូ មូវ៉ាក់គីលី ហ្វាទ្ទីម៉ាស្ទ៍ ត្ទ៍លិក្ទ

(ហ្វាទ្ទីម៉ាស្ទ៍ភរិយារបស់បុរសអតិថិជនរបស់ខ្ញុំត្រូវបានលែងលះ)

តែបើគេស្គាល់ច្បាស់នូវអត្តសញ្ញាណរបស់ភរិយា មិនចាំបាច់ហៅឈ្មោះភរិយានោះទេ ។

បើស្វាមីមិនអាចសូត្រលែងលះ ជាភាសាអារ៉ាប់បានទេ រកអ្នកតំណាងឲ្យសូត្រជួសខ្លួនមិនបានទេ ស្វាមីនោះអាចសូត្រលែងលះតាមភាសាផ្សេងបានដោយបកប្រែ ត្រូវអត្ថន័យនឹងរូបមន្តលែងលះជាភាសាអារ៉ាប់ ។782-2517

## រយៈពេលរង់ចាំពេលលែងលះ (اَلْعِدَّةُ)

មានរដូវខែ ដោយពុំបានដឹងទេថាភរិយានេះមានផ្ទៃពោះនោះ ក្រោយមកស្វាមីនេះទើបបានដឹង (ថាភរិយានោះមានផ្ទៃពោះ ក្នុងអំឡុងពេលដែលនាងកំពុងមានរដូវខែនោះ) ដោយផ្អែកលើច្បាប់ប្រុងប្រយ័តក្រែងខុសឆ្គង ស្វាមីនោះត្រូវលែងលះភរិយានោះសាថ្មី ។

3. ប្រសិនបើ អវត្តមានឬជាប់ឃុំឃាំងខ្លួនក្នុងពន្ធនាគារ ស្វាមីមិនអាចដឹងបានយ៉ាង ពិតប្រាកដទេថាភរិយាជ្រះស្អាតពីហ្វៃជ្ជ៍ឬនីហ្វាស់ហើយឬនៅ ។ តែក្នុងករណីនេះ ដោយផ្អែកលើច្បាប់ប្រុងប្រយ័តក្រែងខុសឆ្គង ស្វាមីត្រូវរង់ចាំយ៉ាងតិចមួយខែ ក្រោយពីបានបែកពីភរិយាខ្លួន ក្រោយពីនេះទើបអាចលែងលះភរិយាបាន ។781-2509

ចាំបាច់ត្រូវតែសូត្រលែងលះ ជាភាសាអារ៉ាប់ត្រឹមត្រូវ ដោយប្រើពាក្យ "ត្ត៏លិក្ក طالِق" និងឲ្យមានមនុស្សត្រឹមត្រូវ (អ្អាឌីល العدل) ពីរនាក់ដឹងឮការលែងលះនេះ ។ បើស្វាមីចង់សូត្រលែងលះដោយខ្លួនឯងផ្ទាល់ ស្វាមីនេះត្រូវថាឈ្មោះភរិយាខ្លួនដែរ ។ ឧទាហរណ៍ បើភរិយាឈ្មោះហ្វាទីម៉ាស្ហ៍ ស្វាមីត្រូវថា៖



تَنَاكَحُوْا تَنَاسَلُوْا تَكْثُرُوْا فَإِنِّيْ أُبَاهِيْ بِكُمُ ٱلْاُمَمَ يَوْمَ الْقِيَامَةِ وَ لَوْ بِالسِّقْطِ

"ចូររៀបមង្គលការអាពាហ៍ពិពាហ៍ ចូរបង្កបង្កើតកូនចៅច្រើនឡើង ព្រោះខ្ញុំﷺនឹងត្រេកអរចំពោះបណ្ដាអ្នកតាមខ្ញុំដ៏ច្រើនក្នុងថ្ងៃគ្ឫយ៉ាម៉ាត់ ទោះបីជាកូនរលូតក៏ដោយ ។"

وَ قَالَ صَلَّى اللّٰهُ عَلَيْهِ وَ آلِهِ اَيْضًا

ព្រះអង្គﷺមានព្រះវចនៈដែរថា៖

النِّكَاحُ مِنْ سُنَّتِيْ فَلَيْسَ مِنِّيْ

"មង្គលការអាពាហ៍ពិពាហ៍ (នីកាស្ហ៍) ជាស៊ុនណាស្ហ៍ខ្ញុំﷺ អ្នកណាគេចចេញពីស៊ុនណាស្ហ៍ខ្ញុំﷺ អ្នកនោះមិនមែនបក្សពួកខ្ញុំﷺទេ ។"

وَ قَالَ سَيِّدُ الْوَصِيِّيْنَ اَمِيْرُ الْمُؤْمِنِيْنَ اِمَامُ الْمَشَارِقِ وَ الْمَغَارِبِ عَلِيُّ بْنُ اَبِيْ طَالِبٍ (صَلَوَاتُ اللّٰهِ عَلَيْهِ)

ព្រះអគ្គមហាប្រមុខរបស់បណ្ដាព្រះឧត្ដរាធិការី អាមីរុល-មុមីនីន صلوات الله عليه والسلام ព្រះរាជសីរបស់អល់ឡោះហ៍ عز وجل ព្រះវិជ័យ

បុរស ព្រះវិជ័យបុរសលើអស់វិជ័យបុរសទាំងពួង ព្រះសន្តអ៊ីម៉ាំនៃទិសខាងកើតនិងទិសខាងលិច អ៊ុលី អ៊ីបនូ អាប៊ីត៏លិប صلوات الله عليه والسلام មានវចនៈថា៖

مَنْ تَزَوَّجَ فَقَدْ اَحْرَزَ نِصْفَ دِيْنِهِ فَلْيَتَّقِ اللهَ فِيْ النِّصْفِ الْآخَرِ

"អ្នកណារៀបមង្គលការអាពាហ៍ពិពាហ៍ អ្នកនោះមាននូវជំនឿពាក់កណ្តាល ដូច្នេះចូរយកចិត្តទុកដាក់អំពីអល់ឡោះហ្វ៍ عز وجل មួយប៉ែកពាក់កណ្តាលទៀត ។"

## របៀបសូត្រនីកាស្ហ់ (ឬ រូបមន្តអាពាហ៍ពិពាហ៍ ឬ ស្ហ៊ីកោះត្ហ៏ صِيغَة)

ទោះបីអាពាហ៍ពិពាហ៍អចិន្ត្រៃយ៍ ឬអាពាហ៍ពិពាហ៍មានកំណត់ពេលក៏ដោយ ការយល់ព្រមរវាងបុរសនិងស្ត្រីដោយមិនប្រកាសឲ្យដឹងឮ ឬដោយសរសេរជាលាយលក្ខណ៍អក្សរនោះមិនគ្រប់គ្រាន់ទេ ។ ចាំបាច់ត្រូវតែសូត្រនីកាស្ហ់ (ឬសូត្ររូបមន្តអាពាហ៍ពិពាហ៍ ឬសូត្រស្ហ៊ីកោះត្ហ៏) នេះ ដើម្បីនឹងឲ្យអាពាហ៍ពិពាហ៍មានសុពលភាពត្រឹមត្រូវ



បុរសត្រូវតែចង់លែងលះភរិយាពិតប្រាកដ ពុំនោះទេ ឧទាករហណ៍ បើបុរសនោះថាលែងលះដោយលេងសើច ការលែងលះនោះមិន មានសុពលភាពទេ គឺមោឃៈ យកជាការពុំបានទេ ។779-2507

ក្នុងពេលលែងលះ ភរិយាចាំបាច់ត្រូវជ្រះស្អាតពីឈាមរដូវខែ (ហៃ្ហដ្ហ៍ الحَيض) និងបាត់ធ្លាក់ឈាមក្រោយពីសម្រាលកូនរួច (នីហ្វាស់ النِفاس) ។ ចាំបាច់ដែរ ស្វាមីមិនត្រូវរួមភេទជាមួយស្ត្រីនោះទេក្រោយអំឡុងពេលមានរដូវខែ ឬមានឈាមក្រោយសម្រាលកូនរួចនេះ ។780-2508

អនុញ្ញាតឲ្យលែងលះភរិយា ទោះបីភរិយានោះកំពុងតែមានឈាមរដូវខែ ឬកំពុងតែមានឈាមក្រោយសម្រាលកូនរួចក៏ដោយ ក្នុងករណីបីគឺ៖

1. បើស្វាមីពុំបានរួមភេទជាមួយភរិយានេះទេ ក្រោយពីបានរៀបការរួច ។

2. បើដឹងថាភរិយានេះមានផ្ទៃពោះ ។ តែប្រសិនបើស្វាមីបានលែងលះភរិយានេះ ក្នុងអំឡុងពេលដែលនាងកំពុង

# ត៏ឡាក់ (ការលែងលះ)

## ត៏ឡាក់ (ការលែងលះ)

ដើម្បីអាចលះលែងភរិយាបាន បុរសត្រូវគ្រប់អាយុនិងមានសតិអារម្មណ៍ល្អ មិនវិកលចរិតទេ ។ បុរសនោះចាំបាច់ត្រូវលែងលះដោយជម្រើសខ្លួនឯងដែរ ។ ដូច្នេះបើបុរសត្រូវគេបង្ខិតបង្ខំឲ្យលែងលះភរិយា ការលែងលះនោះមិនអាចយកជាការបានទេ គឺមោឃៈ ។ ចាំបាច់ដែរ



ស្របតាមច្បាប់អ៊ីស្លាម ។ សូត្រនីកាស់នេះត្រូវថាដោយស្ត្រីនិងបុរសដោយផ្ទាល់ ឬដោយមនុស្សម្នាក់ដែលបុរសនិងស្ត្រីតែងតាំងឲ្យថាឬសូត្រជូសខ្លួន ។

អាចឲ្យមនុស្សតែម្នាក់ជាតំណាងបុរសនិងស្ត្រី រៀងៗខ្លួនបាន ដើម្បីសូត្រនីកាស់អាពាហ៍ពិពាហ៍អចិន្ត្រៃយ៍ឬអាពាហ៍ពិពាហ៍មានកំណត់ពេល ។ អនុញ្ញាតឲ្យបុរសទៅជាអ្នកតំណាងរបស់ស្ត្រីនិងរៀបការអចិន្ត្រៃយ៍ ឬរៀបការមានកំណត់ពេលបានជាមួយស្ត្រីនោះ ។ តែដោយផ្អែកលើច្បាប់ប្រុងប្រយ័តគួរចៀសវាក្រែងខុសឆ្គង ត្រូវមានមនុស្សពីរនាក់សូត្រនីកាស់ (ឬសូត្ររូបមន្តអាពាហ៍ពិពាហ៍ ឬសូត្រស៊ីកោះត៏) ។

បើស្ត្រីនិងបុរស ចង់សូត្ររូបមន្តអាពាហ៍ពិពាហ៍អចិន្ត្រៃដោយខ្លួនឯង ស្ត្រីត្រូវចាប់ផ្តើមដោយសូត្រថា៖

زَوَّجْتُكَ نَفْسِيْ عَلَى اَلصِّدَاقِ اَلْمَعْلُوم

សៅវ៉ាច់ទូកា ណាហ្វ់ស៊ី អាឡាស់-ស៊ីដាក់-គ៊ីល-ម៉ាក់លូម

(ខ្ញុំរៀបការជាមួយលោកដោយមានខាន់ស្លាតាមកំណត់)

បុរសត្រូវតបវិញភ្លាមថា៖

قَبِلْتُ اَلتَّزْوِيْجَ

ក៏ប៊ីលទុត-តាស់វីយ៉ា

(ខ្ញុំយល់ព្រមរៀបការ)

តែបុរសអាចថាវែងបានគឺ៖

قَبِلْتُ اَلتَّزْوِيْجَ عَلَى اَلصِّدَاقِ اَلْمَعْلُومِ

ក៏ប៊ីលទុត-តាស់វីយ៉ា អ៊ុឡាស់-ស៊ីដាក់-គីល-ម៉ាក់លូម

(ខ្ញុំយល់ព្រមរៀបការដោយមានខាន់ស្លាតាមកំណត់ជាស្រេច) ។

រួចស្រេចហើយ អាពាហ៍ពិពាហ៍នឹងមានសុពលភាពត្រឹមត្រូវស្របតាមច្បាប់អ៊ីស្លាម ។

បើស្ត្រីនិងបុរសបានតែងតាំងមនុស្សម្នាក់ ជាតំណាងរៀងៗខ្លួន ដើម្បីសូត្របមន្តអាពាហ៍ពិពាហ៍ជូនខ្លួន ឧទាហរណ៍ បើបុរសឈ្មោះ អាស្ម៉ាដ់ ស្ត្រីឈ្មោះ ហ្វាទីម៉ាស់ អ្នកតំណាងស្ត្រីត្រូវនិយាយដាក់អ្នកតំណាងបុរស (អាស់ម៉ាដ់) មុនថា៖

زَوَّجْتُ مُوَكِّلَكَ أحمد مُوَكِّلَتِي فاطمة عَلَى اَلصِّدَاقِ



# طَلاق

វាបណ្ដាលឲ្យខ្លួនធ្វើទង្វើបាបទេ ឬមិនមានបំណងធ្វើឲ្យបុរសមើលមកលើខ្លួនដោយប្រាថ្នាអាក្រក់ទេ ។ ពុំនោះទេ បើខ្លាចកើតមាននូវប្រការនេះ ស្ត្រីត្រូវបិទបាំងមុខនិងដៃ ។

*មើលខ្លួនស្ត្រីអាវាសៃដែលមិនព្រមបិទបាំងខ្លួន ទោះបីគេបានដាស់តឿនហើយក៏ដោយ មិនត្រូវហាមទេ បើការមើលនោះពុំធ្វើឲ្យមានសម្រើបផ្លូវភេទទេ ពុំមានបំណងផ្លូវភេទនោះទេ ។ អនុញ្ញាតឲ្យអនុវត្តិច្បាប់នេះចំពោះស្ត្រីប្រភេទនេះទាំងអស់ ទោះបីស្ត្រីនោះជាស្ត្រីមុស្លីម មិនមែនស្ត្រីមុស្លីមក៏ដោយ ទាំងមុខនិងដៃ ទាំងប៉ែកឯទៀតរបស់ខ្លួនដែលស្ត្រីនោះមិនធ្លាប់តែបិទបាំង ។

បើបុរសនិងស្ត្រីមិនសះនីកាស់នឹងគ្នា (គឺម៉ាស់រ៉ម) មិនមានបំណងផ្លូវភេទរកគ្នាទេ អ្នកទាំងពីរអាចមើលខ្លួនប្រាណរបស់រៀងៗខ្លួនបាន លើកលែងតែខ្មាស ។



اَلْمَعْلُومِ
សៅវ៉ាច់ទូ មូវ៉ាក់គីឡាកា អាស់ម៉ាដ់ មូវ៉ាក់គីឡាទី
ហ្វាទីម៉ាស់ អ៊ុឡាស់-ស៊ីដ្វាក់-គ៊ីល-ម៉ាក់លូម
(ខ្ញុំរៀបការស្ត្រីអតិថិជនរបស់ខ្ញុំឈ្មោះ ហ្វាទីម៉ាស់
ជាមួយបុរសអតិថិជនរបស់ លោកឈ្មោះ អាស់ម៉ាដ់
ដោយមានខាន់ស្លាតាមកំណត់ជាស្រេច)

អ្នកតំណាងបុរសត្រូវឆ្លើយតបវិញភ្លាមថា៖

قَبِلْتُ التَّزْوِيْجَ لِمُوَكِّلِي أحمد عَلَى اَلصِّدَاقِ اَلْمَعْلُومِ
ក៉ប៊ីលទុត-តាស់វីយ៉ា លីមូវ៉ាក់គីលី អាស់ម៉ាដ់ អ៊ុឡាស់-
ស៊ីដ្វាក់-គ៊ីល-ម៉ាក់លូម
(ខ្ញុំយល់ព្រមរៀបអាពាហ៍ពិពាហ៍នេះឲ្យបុរសអតិថិជន
របស់ខ្ញុំឈ្មោះ អាស់ម៉ាដ់ ដោយមានខាន់ស្លាតាម
កំណត់ជាស្រេច)

រួចស្រេចហើយ អាពាហ៍ពិពាហ៍មានសុពលភាពត្រឹមត្រូវស្របច្បាប់អ៊ីស្លាម ។

ដោយផ្អែកលើច្បាប់ប្រុងប្រយ័តគួរចៀសវាង ក្រែងខុសឆ្គង ចាំបាច់ត្រូវតែឲ្យពាក្យដែលបុរសប្រើនោះដូចពាក្យសម្តីខាងស្ត្រីប្រើដែរ ។ ឧទាហរណ៍ បើស្ត្រីថា៖ "ស្សៅវ៉ាច់ទូកា ណាហ្វ់ស៊ីកា... (ខ្ញុំរៀបការជាមួយលោក...)" បុរសត្រូវថា៖ "ក្ហ៍ប៊ីលទុត-តាស្សវីយ៉ា (ខ្ញុំយល់ព្រមរៀបអាពាហ៍ពិពាហ៍)" កុំថា៖ "ក្ហ៍ប៊ីលទុន នីកាហ្ (قَبِلْتُ اَلنِّكَاحَ)" ។

អនុញ្ញាតឲ្យបុរសនិងស្ត្រី សូត្ររូបមន្តអាពាហ៍ពិពាហ៍មានកំណត់ពេល (មុតអ្ាស្ហ៍) ក្រោយពីបានកំណត់រយៈពេលនិងបានកំណត់ខាន់ស្លាហើយ ។ បើស្ត្រីថា៖

زَوَّجْتُكَ نَفْسِيْ فِي الْمُدَّةِ الْمَعْلُوْمَةِ عَلَى الْمَهْرِ الْمَعْلُوْم

ស្សៅវ៉ាច់ទូកា ណាហ្វ់ស៊ី ហ្វីល-មុដ្ដាទ្ទីល-ម៉ាក់លូម៉ាទ្ទី

អ្អាឡាល់-ម៉ាហ្ស៍រីល-ម៉ាក់លូម

(ខ្ញុំរៀបអាពាហ៍ពិពាហ៍ជាមួយលោកដោយមានរយៈពេលកំណត់និងដោយមានខាន់ស្លាតាមកំណត់ជាស្រេច)

បុរសត្រូវឆ្លើយតបវិញភ្លាមថា៖



ស្រើបក៏ដោយ និងទោះបីដោយខ្លាចឬមិនខ្លាចវាបណ្តាលឲ្យធ្វើទង្វើបាបក៏ដោយ ។ ហាមដែរ (ហ្ារ៉ាំ) មើលមុខនិងដៃរហូតដល់កដៃរបស់ស្ត្រីប្រភេទនេះ (គឺស្ត្រីសៈនីកាស្ហ៍) ដោយមានសម្រើប ឬបើខ្លាចការមើលនេះបណ្តាលឲ្យធ្វើទង្វើបាប ឬដោយផ្អែកទៅលើច្បាប់ប្រុងប្រយ័តគួរចៀសវាងក្រែងខុសឆ្គង បុរសមិនត្រូវមើលមុខឬដៃស្ត្រីទេ ទោះបីដោយគ្មានបំណងបែបនេះក៏ដោយ ។ ដូចគ្នាដែរ ហាមស្ត្រីមើលខ្លួនបុរសសៈនីកាស្ហ៍ (បុរសមិនមែនម៉ាស្ហ៍រ៉ម) លើកលែងតែប៉ែកខ្លួនដែលមិនត្រូវបិទបាំងដូចជាមុខ ដៃ ក្បាល ជើងនិងកជាដើម ។ ស្ត្រីត្រូវមើលប៉ែកទាំងនេះដោយពុំមានសម្រើប ឬបើមិនខ្លាចការមើលនេះអាចបណ្តាលឲ្យធ្វើទង្វើបាបទេ ។

*ស្ត្រីត្រូវបិទបាំងខ្លួននិងសក់ កុំឲ្យបុរសសៈនីកាស្ហ៍ឃើញដោយផ្អែកលើច្បាប់ប្រុងប្រយ័ត គួរចៀសវាងក្រែងខុសឆ្គង ស្ត្រីត្រូវបិទបាំងខ្លួនពីក្មេងប្រុសមិនទាន់គ្រប់អាយុដែរតែអាចដឹងខុសត្រូវដែលអាចមានសម្រើបផ្លូវភេទបានដែរ ។ តែស្ត្រីអាចទុកមុខនិងដៃត្រឹមកដៃទទេបាននៅចំពោះមុខបុរសសៈនីកាស្ហ៍ ដរាបណាស្ត្រីនោះមិនខ្លាច

បានទេ បុរសមុស្លីមក៏មិនអាចរៀបការជាមួយស្ត្រីមិនមែនមុស្លីមបានទេដែរ លើកលែងតែស្ត្រីនោះនៅក្នុងចំណោមជនគម្ពីរ ។ តែគេមិនហាមរៀបការដោយមានកំណត់ពេលជាមួយស្ត្រីកាន់សាសនាយ៉ាហ៊ូឌី និងស្ត្រីកាន់សាសនាគ្រិស្តទេ តែច្បាប់ប្រុងប្រយ័តខ្លាចខុសឆ្គងតម្រូវថាមិនត្រូវរៀបការអចិន្ត្រៃយ៍ ជាមួយពួកស្ត្រីទាំងនេះទេ ។

*មាននិកាយខ្លះដូចជានិកាយខៅវ៉ារីជ្ញ គុឡ្លាត់ និងណាវ៉ាស៊ីប (الناصبي) ជាដើម ដែលតាំងខ្លួនជាមុស្លីម តែត្រូវចាត់ទុកជាបុគ្គលមិនមែនមុស្លីមទេ ។ អាស្រ័យហេតុនេះ បុរសមុស្លីមនិងស្ត្រីមុស្លីមមិនអាចរៀបការអចិន្ត្រៃយ៍ និងមិនអាចរៀបការដោយមានកំណត់ពេល ជាមួយពួកនេះបានទេ ។

## មើលស្ត្រីមិនមែនម៉ាស់រ៉ម (គឺស្ត្រីសះនីកាស់)

*ហាម (ហ្ារ៉ាំ) បុរសមើលខ្លួនឬសក់ស្ត្រីសះនីកាស់ (មិនមែនម៉ាស់រ៉ម) ទោះបីដោយមានបំណងឬមិនមានបំណង



قَبِلْتُ

ក៏ប៊ីលទុ

(ខ្ញុំយល់ព្រម)

រួចស្រេចហើយ អាពាហ៍ពិពាហ៍មានសុពលភាពត្រឹមត្រូវស្របច្បាប់អ៊ីស្លាម ។

អាពាហ៍ពិពាហ៍មុតអ្អាស់នឹងមានសុពលភាព ត្រឹមត្រូវស្របច្បាប់អ៊ីស្លាមដែរ បើបុរសនិងស្ត្រីបានតែងតាំងអ្នកតំណាងរៀងៗខ្លួន ដើម្បីសូត្ររូបមន្តអាពាហ៍ពិពាហ៍ជូនខ្លួន ។ ក្នុងករណីនេះ អ្នកតំណាងស្ត្រីត្រូវនិយាយដាក់អ្នកតំណាងបុរសមុនថា៖

مَتَّعْتُ مُوَكِّلَتِي مُوَكِّلَكَ فِي الْمُدَّةِ الْمَعْلُومَةِ عَلَى الْمَهْرِ الْمَعْلُوْمِ

ម៉ាត់តាក់ទុ មូវ៉ាក់គីឡាទី មូវ៉ាក់គីឡាកា ហ្វីល-មុដ្ដាទីល-ម៉ាក់លូម៉ាទី អាឡាល់-ម៉ាស់រីល-ម៉ាក់លូម

(ខ្ញុំរៀបអាពាហ៍ពិពាហ៍ដោយមានកំណត់ពេលស្ត្រីអតិថិជនខ្ញុំជាមួយបុរសអតិថិជនលោកដោយមានកំណត់

ខាន់ស្លាជាស្រេច)

អ្នកតំណាងបុរសត្រូវឆ្លើយតបវិញភ្លាមថាៈ

قَبِلْتُ التَّزْوِيْجَ لِمُوَكِّلِي هَكَذَا

ក៏ប៊ីលទុត-តាស្វ៊ីយ៉ា លីមូវ៉ាក់គីលី ហាកាសា
(ខ្ញុំព្រមរៀបអាពាហ៍ពិពាហ៍នេះឲ្យបុរសអតិថិជនខ្ញុំដោយរបៀបនេះ)

## លក្ខខណ្ឌសូត្ររូបមន្តអាពាហ៍ពិពាហ៍ (صِيغَة)

មានលក្ខខណ្ឌខ្លះក្នុងការសូត្ររូបមន្តអាពាហ៍ពិពាហ៍ គឺៈ

១. ដើម្បីប្រុងប្រយ័តខ្លាចមានការខុសឆ្គង ត្រូវថារូបមន្តអាពាហ៍ពិពាហ៍ជាភាសាអារ៉ាប់ត្រឹមត្រូវ ។ បើបុរសនិងស្ត្រីមិនអាចសូត្ររូបមន្តអាពាហ៍ពិពាហ៍ ជាភាសាអារ៉ាប់ត្រឹមត្រូវបានទេ ពួកគេអាចសូត្រជាភាសាដទៃបាន មិនបាច់តែងតាំងអ្នកតំណាងទេ ។ តែពាក្យដែលប្រើក្នុងការបកប្រែនោះ ត្រូវមានអត្ថន័យត្រូវគ្នានឹងពាក្យអារ៉ាប់ "ស៊ៅវ៉ាច់ទូ" (ខ្ញុំរៀបអាពាហ៍ពិពាហ៍) និង "ក៏ប៊ីលទូ" (ខ្ញុំ



អចិន្ត្រៃយ៍ក៏ដោយ ទោះបីអាពាហ៍ពិពាហ៍មានកំណត់ពេលក៏ដោយ បុរសនោះមិនអាចរៀបការជាមួយបងស្រី/ប្អូនស្រីរបស់ភរិយាខ្លួនទេ ដរាបណាគូស្វាមីភរិយានៅតែរៀបការនឹងគ្នា ។

ស្វាមីមិនមានសិទ្ធិរៀបការ ជាមួយបណ្ដាក្មួយស្រីរបស់ភរិយាខ្លួនទេ បើភរិយាខ្លួនមិនអនុញ្ញាតទេនោះ ។ តែបើស្វាមីបានរៀបការជាមួយក្មួយស្រីរបស់ភរិយាខ្លួន ដោយពុំបានទទួលការអនុញ្ញាតពីភរិយាខ្លួនជាមុនទេ ក្រោយមកភរិយាខ្លួនបានអនុញ្ញាត អាពាហ៍ពិពាហ៍នោះត្រឹមត្រូវ ។

*បើភរិយាដឹងថាស្វាមីនាង បានរៀបការជាមួយក្មួយស្រីនាង ហើយមិនបានប្រាប់នាងឲ្យដឹងទេ បើក្រោយមកនាងយល់ព្រមអាពាហ៍ពិពាហ៍នោះត្រឹមត្រូវ ។ បើក្រោយមកនាងមិនយល់ព្រមទេ អាពាហ៍ពិពាហ៍នោះត្រូវមោឃៈ ។

*ស្ត្រីមុស្លីមមិនអាចរៀបការ ជាមួយបុរសមិនមែនមុស្លីម

ស្វាមីភរិយា) ។

ម្ដាយមីង/ម្ដាយធំខាងឪពុក និងខាងម្ដាយរបស់បុរស ម្ដាយមីង/ម្ដាយធំខាងឪពុក និងខាងម្ដាយរបស់ឪពុករបស់បុរស ម្ដាយមីង/ម្ដាយធំខាងឪពុកនិងខាងម្ដាយរបស់ជីតាខាងឪពុករបស់បុរស ម្ដាយមីង/ម្ដាយធំខាងឪពុកនិងខាងម្ដាយរបស់ម្ដាយរបស់បុរស ម្ដាយមីង/ម្ដាយធំខាងឪពុក និងខាងម្ដាយរបស់យាយរបស់បុរស ។ល ។ ជាម៉ាស្ហ៊ុរ៉មរបស់បុរស ។

ឪពុកនិងជីតារបស់ស្វាមី និងបណ្ដាសាច់លោហិតប្រុសៗឡើងលើរបស់ស្វាមីជា ម៉ាស្ហ៊ុរ៉មរបស់ភរិយា ។ ដូចគ្នាដែរ កូនប្រុសៗនិងចៅប្រុសរបស់ស្វាមី (ពោលគឺ កូនប្រុសៗរបស់កូនប្រុសនិងរបស់កូនស្រីៗរបស់ស្វាមី) និងបណ្ដាកូនចៅប្រុសបង្កើតរបស់ពួកគេ ជាម៉ាស្ហ៊ុរ៉មរបស់ភរិយា ទោះបីពួកគេទាំងអស់នោះកើតហើយក៏ដោយ ពេលរៀបការ ឬកើតក្រោយពីបានរៀបការហើយក៏ដោយ ។

បើបុរសរៀបការជាមួយស្ត្រី ទោះបីអាពាហ៍ពិពាហ៍



យល់ព្រម) ។

២. បុរសនិងស្ត្រីឬអ្នកតំណាងពួកគេ ដែលសូត្រនីកាស្ហ៍នោះត្រូវធ្វើក្នុងបំណង (នៀត) អ៊ីនស្ហាអ៍ (إنشاء ពោលគឺសូត្រក្នុងន័យឲ្យកើតជាការ ឲ្យអាពាហ៍ពិពាហ៍កើតមានឡើងបានសម្រេច) ។ អាចនិយាយបានម្យ៉ាងទៀតថា ពេលស្ត្រីសូត្រថា "ស៊ៅវ៉ាច់តូកា ណាហ្វ៊ស៊ី" ស្ត្រីនោះមានបំណងថា ខ្លួនជាភរិយារបស់បុរសនេះប្រាកដមែន ។ ពេលបុរសឆ្លើយតបវិញ បុរសនោះត្រូវមានបំណងថា "ក៏ប៊ីលទុត-តាស្ហ៊ីយ៉ា" បុរសនោះត្រូវមានបំណងថាខ្លួនព្រមទទួលស្ត្រីនេះជាភរិយាខ្លួនពិតមែន ។ ដូចគ្នាដែរ បើបុរសនិងស្ត្រីតែងតាំងអ្នកតំណាងឲ្យសូត្រនីកាស្ហ៍ជួសខ្លួនពេលថា "ស៊ៅវ៉ាច់តូ" និង "ក៏ប៊ីលតូ" អ្នកតំណាងទាំងនោះត្រូវមានបំណងក្នុងចិត្ត ថាបុរសនិងស្ត្រីដែលបានតែងតាំងខ្លួនជាអ្នកតំណាងនោះ ទៅជាស្វាមីនិងភរិយាពិតប្រាកដមែន ។

៣. អ្នកសូត្រនីកាស្ហ៍ សាមីខ្លួនឬអ្នកតំណាង ត្រូវមានស្មារតីល្អ (មិនឆ្កួតឬមិនខ្វះខាតប្រាជ្ញាទេ) ដើម្បីប្រុងប្រយ័តក្រែងខុសឆ្គង អ្នកនោះត្រូវគ្រប់អាយុ (បាលិគ្ហ៍) ។

៤. បើអ្នកសូត្រនីកាស់ ជាអ្នកតំណាងឬជាអាណាព្យាបាល (វ៉ាលី) របស់បុរសនិងស្ត្រី អ្នកនោះត្រូវប្រាប់ឈ្មោះបុរសនិងស្ត្រីផងឬចង្អុលទៅរកបុរសនិងស្ត្រីនោះ ។ ដូច្នេះ បើបុគ្គលដែលមានកូនស្រីច្រើននាក់ ធ្វើវ៉ាលី (អាណាព្យាបាល) ឲ្យកូនស្រីម្នាក់ ពេលសូត្រនីកាស់ដាក់បុរសថា៖ زَوَّجْتُكَ إِحْدٰى بَنَاتِي ស៊ៅវ៉ាច់ទូកា អ៊ិះហ្ដា បាណាទី (ខ្ញុំរៀបការកូនស្រីខ្ញុំម្នាក់ឲ្យលោក) បុរសឆ្លើយតបវិញថា៖ قَبِلْتُ ក៏បឹលទូ (ខ្ញុំយល់ព្រម) អាពាហ៍ពិពាហ៍មិនមានសុពលភាពទេ គឺត្រូវមោឃៈ ពីព្រោះមិនបានបង្ហាញកូនស្រីឲ្យស្គាល់ ។

៥. បុរសនិងស្ត្រីត្រូវចង់ចងស្ពានមេត្រីជាមួយគ្នា (គឺចង់រៀបការជាគូស្វាមីភរិយានឹងគ្នា) ។ តែបើស្ត្រីបង្ហាញឲ្យឃើញថាស្ទាក់ស្ទើរពេលឆ្លើយយល់ព្រម តែគេដឹងថានៅក្នុងចិត្តស្ត្រីនោះ ស្ត្រីនោះចង់រៀបការមែន អាពាហ៍ពិពាហ៍នេះមានសុពលភាពត្រឹមត្រូវស្របច្បាប់ ។

បើ ពេលសូត្រអាពាហ៍ពិពាហ៍ សូម្បីតែសូត្រមិនត្រូវពាក្យមួយគត់ដែលធ្វើឲ្យខុសអត្ថន័យក៏ដោយ អាពាហ៍ពិពាហ៍



បើបុរសណារៀបការជាមួយស្ត្រី ម្ដាយរបស់ស្ត្រីនេះ យាយខាងម្ដាយរបស់ស្ត្រីនេះ យាយខាងឪពុករបស់ស្ត្រីនេះ ។ល ។ ទៅជាម៉ាស៊្ហរ៉មរបស់បុរសនោះ ទោះបីបុរសនោះពុំបានផ្សំដំណេក (គឺរួមភេទ) ជាមួយស្ត្រីនេះក៏ដោយ ។

បើបុរសណារៀបការជាមួយស្ត្រី បានផ្សំដំណេក (គឺបានរួមភេទ) កូនស្រីរបស់ភរិយា ចៅស្រីរបស់ភរិយា (កូនស្រីរបស់កូនប្រុសរបស់ភរិយា និងកូនស្រីរបស់កូនស្រីរបស់ភរិយា) និងបណ្ដាកូនចៅស្រីរបស់ពួកនាងទៅជាម៉ាស៊្ហរ៉មរបស់បុរស ទោះបីពួកនាងទាំងនោះកើតហើយក៏ដោយនៅពេលរៀបការ ឬកើតក្រោយពីបានរៀបការរួចហើយក៏ដោយ ។

បើបុរសរៀបការជាមួយស្ត្រី តែពុំបានរួមភេទទេ ច្បាប់ប្រុងប្រយ័តខ្លាចខុសឆ្គង មិនឲ្យរៀបការជាមួយកូនស្រីរបស់ភរិយាទេ ដរាបណានៅតែមានអាពាហ៍ពិពាហ៍ (ពោលគឺ បុរសនិងភរិយានៅតែរួមរស់ជាមួយគ្នាជាគូ

៣. បើភរិយាដឹងថា ក្នុងពេលរៀបអាពាហ៍ពិពាហ៍ ស្វាមីខ្លួនមានរោគឃ្លង់ឬរោគសើស្បែកសដុបៗ ។

**សេចក្តីបញ្ជាក់** - បើភរិយាមានស្វាមី ដែលពុំអាចរួមភេទបាន ចង់លុបចោលអាពាហ៍ពិពាហ៍ ភរិយានោះចាំបាច់ត្រូវជួបលោកមុក្ខតាហ្វ៊ីដូ (លោកអាជ្ញាធរជំនាញច្បាប់សាសនា) ឬអ្នកតំណាង លោកមុក្ខតាហ្វ៊ីដូឬអ្នកតំណាងអាចទុកពេលមួយឆ្នាំឲ្យស្វាមី បើក្រោយពីរយៈពេលនេះស្វាមីនៅតែមិនអាចរួមភេទជាមួយភរិយា ឬជាមួយភរិយាម្នាក់ទៀតបានទេ ភរិយាខ្លួនអាចរំលាយអាពាហ៍ពិពាហ៍បាន ។

## មនុស្សដែលហាមរៀបការជាមួយ

ហាមរៀបការជាមួយស្ត្រីម៉ាស្ហ៊រ៉ម (គឺមិនសះនីកាស្ហ៊) របស់ខ្លួន ពោលគឺ ម្តាយ បងស្រី/ប្អូនស្រី កូនស្រី ម្តាយមីង/ម្តាយធំខាងឪពុក ម្តាយមីង/ម្តាយធំខាងម្តាយ ក្មួយស្រី (កូនស្រីរបស់បងប្រុស/ប្អូនប្រុស ឬកូនស្រីរបស់បងស្រី/ប្អូនស្រី) និងម្តាយក្មេក ។



នឹងមោឃៈ (គឺខូចយកជាការមិនបានទេ) ។

បើស្ត្រីគ្រប់អាយុ ព្រហ្មចារីនិងដឹងខុសត្រូវ ចង់រៀបការស្ត្រីនោះត្រូវសូមអនុញ្ញាតពីឪពុកឬជីតាខាងឪពុក ទោះបីស្ត្រីនោះចិញ្ចឹមខ្លួនឯងបាន ដោយមិនពឹងពាក់អ្នកណាក៏ដោយ ។ តែស្ត្រីនោះមិនចាំបាច់សូមអនុញ្ញាតពីម្តាយពីបងប្អូនប្រុសឬសាច់ញាតិឯទៀតទេ ។

## ប្រការដែលបណ្តាលឲ្យអាពាហ៍ពិពាហ៍មោឃៈ

បើស្វាមីទើបនឹងដឹង ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួចថាភរិយាខ្លួនមានកង្វះ លក្ខណៈណាមួយក្នុងចំណោមកង្វះលក្ខណៈទាំងប្រាំមួយប្រការខាងក្រោនេះ ក្នុងពេលរៀបអាពាហ៍ពិពាហ៍ ស្វាមីនោះអាចលុបចោលអាពាហ៍ពិពាហ៍នោះបាន គឺៈ

១. វិបត្តិស្មារតី ទោះបីវិបត្តិនោះលស់ពេលក៏ដោយ (គឺម្តងឆ្កួត ម្តងជា) ។

២. រោគឃ្លង់ ។

៣. រោគសើស្បែកសដុបៗ ។

៤. ខ្វាក់ភ្នែក ។

៥. កាយវិកល ទោះបីមិនដល់ថ្នាក់ដើរមិនរួចក៏ដោយ ។

៦. មានសាច់ឬឆ្អឹងនៅក្នុងយោនី (ខ្មាសស្ត្រី) ទោះបីវាអាចជាឧបសគ្គ ឬមិនអាចជាឧបសគ្គក្នុងការរួមភេទឬក្នុងការមានផ្ទៃពោះក៏ដោយ ។ បើស្វាមីដឹងថាក្នុងពេលកំពុងរៀបអាពាហ៍ពិពាហ៍នោះ ភរិយាខ្លួនមានរោគ អ៊ីហ្វដ៏អ៊ុំ (إفضاء ពេលទ្វារនោម និងទ្វាររដូវខែ ឬទ្វាររដូវខែនិងទ្វារលាមកជាទ្វារតែមួយ) ស្វាមីមិនអាចលុបអាពាហ៍ពិពាហ៍ចោលបានទេ ។ ដោយផ្អែកលើច្បាប់ប្រុងប្រយ័តខ្លាចខុសឆ្គង បើចង់លុបចោលអាពាហ៍ពិពាហ៍ ស្វាមីត្រូវប្រាប់ជាផ្លូវការថាខ្លួនចង់លែងលះ ។

ភរិយាអាចលុបអាពាហ៍ពិពាហ៍ចោលបាន ក្នុងករណីខាងក្រោមនេះ ដោយមិនបាច់លែងលះទេ គឺ៖

១. បើភរិយាទើបនឹងដឹងថាស្វាមីខ្លួនពុំមានលិង្គ ។

២. បើភរិយាទើបនឹងដឹងថាលិង្គរបស់ស្វាមីខ្លួនដាច់ ឬ



កំបុត មុនឬក្រោយផ្សំដំណេក (គឺរួមភេទ) ។

៣. បើភរិយាទើបនឹងដឹងថា ស្វាមីខ្លួនមានជម្ងឺនីមួយដែលបណ្ដាលឲ្យពុំមានសមត្ថភាពរួមភេទ ទោះបីមានជម្ងឺនេះក្រោយពីរៀបការរួច មុនឬក្រោយពីបានផ្សំដំណេក (គឺរួមភេទ) ក៏ដោយ ។

នៅក្នុងករណីតទៅ បើភរិយាមិនព្រមនៅជាមួយស្វាមីតទៅទៀតទេ ចង់លុបចោលអាពាហ៍ពិពាហ៍ ដោយផ្អែកលើច្បាប់ប្រុងប្រយ័តខ្លាចខុសឆ្គង ស្វាមីឬអាណាព្យាបាល (វ៉ាលី) របស់ស្ត្រីត្រូវប្រាប់ជាផ្លូវការថាលែងលះគ្នា ។ គឺករណី៖

១. បើភរិយាដឹងក្រោយពីបានរៀបការរួចថាស្វាមីខ្លួនមានវិបត្តិស្មារតី ក្នុងពេលកំពុងរៀបអាពាហ៍ពិពាហ៍ ឬបើស្វាមីមានវិបត្តិស្មារតីក្រោយរៀបការរួច មុនឬក្រោយពីបានផ្សំដំណេក (គឺរួមភេទ) ។

២. បើភរិយា ក្នុងពេលរៀបអាពាហ៍ពិពាហ៍ ដឹងថាស្វាមីខ្លួនជាមនុស្សកម្រៀវ (គឺគ្មានលិង្គ) ។